00918012

002/19-09-2007-ECCC/TC
E1/176

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 06 / 2013
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ សុក្រ ទី ២៩ ខែ មីនា ឆ្នាំ ២០១៣

## សវនាការ- ថ្ងៃទី ១៦៣

រៀបចំដោយ: សែ កុលវុឌ្ឍី និង Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Roger Phillips |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក William SMITH, លោក Dale LYSAK |
| ជនជាប់ចោទ៖ លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, |

| |
|---|
| លោក ឡៅ ជុនធី, លោក ហុង គីមសួន, លោកស្រី Christine MARTINEAU, លោកស្រី ជេត វណ្ណលី, លោកស្រី Beini YE |
| អ្នកជំនាញ៖ មិនមាន |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី៖ មិនមាន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី សួ សុទ្ធាវី, លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោកស្រី Susan LAMB, លោក Elburg van BOETZELAER |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៣ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ០៩.២០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ២០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការនីតិវិធី | អង្គជំនុំជម្រះ | ០៩.០៣ | ០៩.០៤ |
| សេចក្តីសម្រេចផ្ទាល់មាត់ស្តីពីសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ | អង្គជំនុំជម្រះ | ០៩.០៤ | ០៩.០៥ |
| សេចក្តីសម្រេចផ្ទាល់មាត់ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿងលេខ ០០២ | អង្គជំនុំជម្រះ | ០៩.០៥ | ០៩.១២ |
| កាលវិភាគនៃការធ្វើសវនាការ | អង្គជំនុំជម្រះ | ០៩.១២ | ០៩.២១ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការលះបង់សិទ្ធិមានវត្តមាននៅក្នុងដំណើរការសវនាការ**

ជនជាប់ចោទ នួន ជា អវត្តមានពីកិច្ចដំណើរការសវនាការដោយមូលហេតុសុខភាព និង បានលះបង់សិទ្ធិមានវត្តមានពីដំណើរការសវនាការសម្រាប់រយៈពេលពេញមួយថ្ងៃ។

**សេចក្តីសម្រេចផ្ទាល់មាត់ស្តីពីសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ**

ថ្វីត្បិតជនជាប់ចោទ នួន ជា មានអាយុច្រើន និងមានសុខភាពផ្លូវកាយទន់ខ្សោយក៏ដោយ ក៏របាយការណ៍ និងសក្ខីកម្មនាពេលថ្មីៗរបស់អ្នកជំនាញវេជ្ជសាស្ត្រដែលតុលាការបានចាត់តាំងបានបញ្ជាក់ច្បាស់ថា ជនជាប់ចោទ នួន ជា នៅតែមានសម្បទាចូលរួមសវនាការប្រកបដោយអត្ថន័យ។ ផ្អែកលើការសន្និដ្ឋានរបស់អ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូងតម្កល់នូវសេចក្តីសម្រេចខ្លួនពីពេលកន្លងទៅ ដែលបានថាជនជាប់ចោទ នួន ជា មានកាយសម្បទា និងសតិបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងដែលមានសំអាងហេតុពេញលេញលើបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងនឹងចេញនាពេលសមស្របឆាប់ៗខាងមុខ។

**<u>សេចក្តីសម្រេចផ្ទាល់មាត់ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿងលេខ០០២</u>**

ដោយផ្អែកលើសំអាងហេតុជាលាយលក្ខណ៍អក្សរ ដែលនឹងចេញនាពេលខាងមុខអង្គជំនុំជម្រះសាលាដំបូងសម្រេចតម្កល់នៅដីកាបំបែកកិច្ចដំណើរការនីតិវិធីសវនាការរបស់ខ្លួន ដែលបានចេញកាលពីលើកមុន ដោយអនុលោមតាមវិធាន៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ដោយកំណត់វិសាលភាពនៃការជំនុំជម្រះនៅដំណាក់កាលដំបូងក្នុងសំណុំរឿង០០២ គឺសំណុំរឿង០០២/០១ ត្រឹមតែលើការជម្លៀសប្រជាជនក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។ សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលនឹងមានសំអាងហេតុពេញលេញគ្រប់គ្រាន់លើបញ្ហានេះ អង្គជំនុំជម្រះនឹងចេញក្នុងពេលវេលាសមស្របឆាប់ៗខាងមុខផងដែរ។

**<u>កាលវិភាគនៃការធ្វើសវនាការ</u>**

អង្គជំនុំជម្រះបានជូនដំណឹងថាសវនាការនឹងបន្តនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ ដើម្បីបញ្ចប់ការស្តាប់សក្ខីកម្មសាក្សី TCW-100 និងបន្ទាប់មកស្តាប់សក្ខីកម្មសាក្សី TCW-536។ លោកស្រីចៅក្រម Cartwright បានបន្ថែមថាថវិកាសម្រាប់បុគ្គលិកជាតិនឹងអាចធានាបានរហូតដល់ដំណាច់ខែ មេសា ឆ្នាំ ២០១៣។ បន្ថែមពីលើនេះ អង្គជំនុំជម្រះបានស្នើសុំឲ្យភាគីទាំងអស់ដាក់សារណាទាក់ទងទៅនឹងសាក្សី និងអ្នកជំនាញផ្សេងៗដែលត្រូវចូលខ្លួនមកផ្តល់សក្ខីកម្មនៅសប្តាហ៍បន្តបន្ទាប់ នៅពីថ្ងៃទី០៨ ខែមេសា ដោយសារបញ្ហានេះតម្រូវឲ្យអង្គជំនុំជម្រះទទួលបន្ទុករៀបចំការចាត់ចែងការរៀបចំសវនាការ។ ការខកខានមិនបានដាក់សំណើសុំបែបនេះគឺថា ភាគីមិនអាចដាក់សំណើសុំស្តាប់សក្ខីកម្មសាក្សីដែលភាគីដទៃទៀត ឬក៏ស្នើសុំកំណត់កាលបរិច្ឆេទសម្រាប់កាលបរិច្ឆេទខាងមុខទៀតនៅសំណុំរឿង០០២/០១ បានទេ។

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- សេចក្តីសម្រេចលើសម្បទាចូលរួមសវនាការរបស់ជនជាប់ចោទ នួន ជា បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានទទួលរបាយការណ៍របស់អ្នកជំនាញបានស្តាប់ និងពិភាក្សាដេញដោលលើរបាយការណ៍របស់អ្នកជំនាញចំនួនពីររូប គឺសាស្ត្រាចារ្យ ចន ខាំប៊ែល អ្នកជំនាញផ្នែកជំងឺមនុស្សចាស់ និងលោកវេជ្ជបណ្ឌិត ស៊ីណា ហ្វាស៊ែល ជាអ្នកជំនាញផ្នែកវិកលវិទ្យាកាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៣ កន្លងទៅនេះ ហើយអ្នកជំនាញទាំងពីរនេះត្រូវបានអង្គជំនុំជម្រះចាត់តាំងឲ្យពិនិត្យវាយតម្លៃពាក់ព័ន្ធនឹងបញ្ហាសុខភាព និងសម្បទាចូលរួមសវនាការរបស់ជនជាប់ចោទ នួន ជា។
- ដោយផ្អែកលើសំអាងហេតុជាលាយលក្ខណ៍អក្សរ ដែលនឹងចេញនាពេលខាងមុខអង្គជំនុំជម្រះសាលាដំបូងសម្រេចតម្កល់នៅដីកាបំបែកកិច្ចដំណើរការនីតិវិធីសវនាការរបស់ខ្លួន ដែលបានចេញកាលពីលើកមុន ដោយអនុលោមតាមវិធាន៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ដោយកំណត់វិសាលភាពនៃការជំនុំជម្រះនៅដំណាក់កាលដំបូងក្នុងសំណុំរឿង០០២ គឺសំណុំរឿង០០២/០១ ត្រឹមតែលើការជម្លៀសប្រជាជនក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ វេលាម៉ោង ៩ ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលវុឌ្ឍី Roger PHILLIPS